# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា
## ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ
## មជ្ឈមណ្ឌលអប់រំ

440 NORTH BROAD STREET, ជាន់ទី២ ច្រកចូល C
PHILADELPHIA, PENNSYLVANIA 19130

Renee Queen Jackson
*នាយិការង*

**ទូរស័ព្ទ៖ (២១៥) ៤០០-៤២៧០**
ទូរសារ៖ (២១៥) ៤០០-៤២៧១


ជូនចំពោះមាតាបិតា/អាណាព្យាបាល៖

ដោយសារមានអំពើហឹង្សាកើតឡើងនៅតាមសាលាទូទាំងប្រទេស ក្នុងពេលថ្មីៗនេះ វាជាការចាំបាច់ដើម្បីរៀបចំជាថ្មីឲ្យមានសន្តិសុខនៅក្នុងទីកន្លែងនៃកម្មវិធី Head Start របស់យើង។ ចាប់ផ្តើមនៅថ្ងៃពុធ ទី៣ ខែមេសា ឆ្នាំ២០១៣ នេះ នឹងចាប់អនុវត្តវិធីសាស្រ្តដែលធ្វើឲ្យមានសុវត្ថិភាព នៅពេល មកដល់/ចេញពី កម្មវិធី Head Start នៅសាលា Feltonville។ យើងអនុវត្តវិធីសាស្រ្តទាំងនេះ គឺដើម្បីឲ្យក្មេងរបស់យើងទាំងអស់មានសុវត្ថិភាព។

ក្មេងនឹងតម្រង់ជួរនៅក្នុងទីធ្លាសាលា នៅម៉ោង ៨:៣០ ព្រឹក។ សូមរង់ចាំជាមួយកូនលោកអ្នក រហូតដល់ពេលគ្រូនាំសិស្សចូលក្នុងអាគារ។ ការចុះហត្ថលេខាទទួលក្មេងចូលរៀននឹងធ្វើឡើងនៅក្នុងទីធ្លាសាលា។ បើកូនរបស់លោកអ្នកមកដល់យឺត សមាជិកនៃបុគ្គលិកនឹងទទួលលោកអ្នកនៅមាត់ទ្វារ ដែលជាកន្លែងសម្រាប់លោកអ្នកចុះហត្ថលេខាប្រគល់ក្មេងឲ្យចូលរៀន។ សមាជិកនៃបុគ្គលិកនឹងជូនកូនលោកអ្នកទៅកាន់បន្ទប់រៀន។

ក្មេងនឹងតម្រង់ជួរនៅក្នុងទីធ្លាសាលា នៅវេលាម៉ោង ៣:០០ រសៀល។ ការចុះហត្ថលេខាទទួលក្មេងចេញពីរៀននឹងធ្វើឡើងនៅក្នុងទីធ្លាសាលា។ នៅពេលហួសម៉ោងដែលត្រូវមកទទួលក្មេង គេនឹងនាំសិស្សានុសិស្សដែលមិនទាន់មានអ្នកណាមកទទួល ទៅបន្ទប់នៅក្នុងអាគារសម្រាប់អ្នកដែលមកទទួលក្មេងយឺតពេល ជាមួយបុគ្គលិកមើលក្មេងដែលគេមកទទួលយឺតពេល។ នៅពេលដែលអ្នកមកទទួលក្មេងមកដល់ បុគ្គលិកនឹងមើលបញ្ជាក់នូវអត្តសញ្ញាណប័ណ្ណ ហើយចម្លងអត្តសញ្ញាណប័ណ្ណនោះទុក បើសិនជាគ្មាននៅក្នុងសំណុំឯកសារ។ នៅពេលដែលគេបានមើលបញ្ជាក់អត្តសញ្ញាណប័ណ្ណរួចហើយ គេនឹងប្រគល់កូនរបស់លោកអ្នកឲ្យទៅអ្នកមកទទួលក្មេង។ សូមធ្វើយ៉ាងណាឲ្យបញ្ជីឈ្មោះអ្នកមកទទួលកូនរបស់លោកអ្នក មានព័ត៌មានទាន់សភាពការណ៍ថ្មីៗ។

សូមជម្រាបឲ្យគ្រូដឹងជាមុននៅពេលព្រឹក បើសិនជាលោកអ្នកត្រូវការឲ្យកូនចេញមុនម៉ោង នៅថ្ងៃរសៀល។ ពេលមកយកកូនរបស់លោកអ្នកមុនម៉ោង គេនឹងសុំឲ្យលោកអ្នកបញ្ជាក់ពីខ្លួនរបស់លោកអ្នកនៅត្រង់ទ្វារចូល ប្រាប់ឈ្មោះកូន និងលេខបន្ទប់។ សមាជិកនៃបុគ្គលិក នឹងនាំកូនលោកអ្នកទៅកាន់ទ្វារ ដើម្បីប្រគល់ជូនលោកអ្នក។

គោលបំណងនៃច្បាប់នេះ គឺធ្វើឲ្យមាន សន្តិសុខ និងសុវត្ថិភាព នៅក្នុងអាគារ និងសុវត្ថិភាពដល់ក្មេងទាំងអស់ដែលរៀនក្នុងកម្មវិធី Head Start នៅសាលា Feltonville។ សូមអរគុណចំពោះការសហការរបស់លោកអ្នកជាមួយច្បាប់ថ្មីនេះ។ ខ្ញុំសង្ឃឹមថា ក្រៅពីធ្វើឲ្យកូនលោកអ្នកមានសុវត្ថិភាព ច្បាប់នេះក៏ធ្វើឲ្យក្រុមគ្រួសាររបស់យើងគ្មានការភ័យព្រួយ ដោយដឹងថាការចូលក្នុងអាគារគឺមានសុវត្ថិភាព។

បើសិនជាលោកអ្នកមានសំណួរអ្វី អាចទូរស័ព្ទមកនាងខ្ញុំលេខ ២១៥-៤០០-៥៣២។

សូមអរគុណ

Sandra Snyder
អ្នករៀបចំផ្នែកអប់រំ តំបន់៤